# ទណ្ឌកម្មចំពោះការមិនគោរពវិធានការ
# ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## **បទគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក** *(មាត្រា៧ នៃច្បាប់ និងមាត្រា២២ នៃអនុក្រឹត្យ)*

- បទគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **១ លានរៀល** ទៅ **៥ លានរៀល** (បើមិនបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ)។
- បទគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **៦ ខែ** ទៅ **៣ ឆ្នាំ** និងពិន័យជាប្រាក់ពី **២ លានរៀល** ទៅ **១០ លានរៀល** (បើបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ)។

## **បទគេចវេះពីការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល** *(មាត្រា៨ នៃច្បាប់)*

- បទគេចវេះពីការតម្រូវឱ្យទទួលការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១ ឆ្នាំ** ទៅ **៥ ឆ្នាំ** និងពិន័យជាប្រាក់ពី **៥ លានរៀល** ទៅ **២០ លានរៀល**។
- បទគេចវេះពីការតម្រូវឱ្យទទួលការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **៥ ឆ្នាំ** ទៅ **១០ ឆ្នាំ** (បើបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ)។

## **បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ** *(មាត្រា៩ នៃច្បាប់)*

- បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **៥ ឆ្នាំ** ទៅ **១០ ឆ្នាំ**។
- បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១០ ឆ្នាំ** ទៅ **២០ ឆ្នាំ** (បើបានធ្វើឡើងដោយមានការរៀបចំជាក្រុម ឬអង្គការចាត់តាំង)។

## **បទមិនគោរពវិធានការរដ្ឋបាល** *(មាត្រា១០ នៃច្បាប់)*

- បទមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **១ លានរៀល** ទៅ **៥ លានរៀល**។
- បទមិនគោរពវិធានការរដ្ឋបាលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **៦ ខែ** ទៅ **៣ ឆ្នាំ** និងពិន័យជាប្រាក់ពី **២ លានរៀល** ទៅ **១០ លានរៀល** (បើបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ)។
- បទមិនគោរពវិធានការរដ្ឋបាលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **២ ឆ្នាំ** ទៅ **៥ ឆ្នាំ** និងពិន័យជាប្រាក់ពី **៥ លានរៀល** ទៅ **២០ លានរៀល** (កាលបើអំពើខាងលើនេះបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ)។

**រៀបចំដោយៈ ក្រសួងយុត្តិធម៌**

## បទរារាំងដល់ការអនុវត្តវិធានការ *(មាត្រា១១ នៃច្បាប់)*

- បទរារាំង ឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការ ដែលបានដាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **៦ ខែ** ទៅ **៣ ឆ្នាំ** និងពិន័យជាប្រាក់ពី **២ លានរៀល** ទៅ **១០ លានរៀល**។
- បទរារាំង ឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **២ ឆ្នាំ** ទៅ **៥ ឆ្នាំ** និងពិន័យជាប្រាក់ពី **៥ លានរៀល** ទៅ **២០ លានរៀល** (បើបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ)។

## ការមិនអនុវត្តកាតព្វកិច្ចពាក់ម៉ាស - *សម្រាប់បុគ្គល*
*(មាត្រា៥ និងមាត្រា១៩ នៃអនុក្រឹត្យ)*

- យោងតាមមាត្រា៥ នៃអនុក្រឹត្យ ការពាក់ម៉ាស ត្រូវធ្វើជាកាតព្វកិច្ចដោយផ្អែកតាមសកម្មភាពការងារ ឬស្ថានភាពមុខរបររបស់បុគ្គល និងនៅតាមទីកន្លែងដែលមានហានិភ័យនៃការចម្លងឬការឆ្លងមេរោគកូវីដ-១៩។
- ផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលត្រូវចេញប្រកាស ឬសេចក្តីសម្រេច ដើម្បីកំណត់អំពីបុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស និងទីកន្លែងដែលតម្រូវឱ្យមានការពាក់ម៉ាស។ ផ្អែកតាមការកំណត់នេះ បុគ្គលដែលបំពាននឹងកាតព្វកិច្ចពាក់ម៉ាស ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖
    - ការបំពានលើកទី១ ៖ ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច
    - ការបំពានចាប់ពីលើកទី២ ៖ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **២ សែនរៀល** ទៅ **១ លានរៀល**។

## ការមិនអនុវត្តកាតព្វកិច្ចទាក់ទងនឹងការពាក់ម៉ាស - *សម្រាប់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម*
*(មាត្រា៦ និងមាត្រា២០ នៃអនុក្រឹត្យ)*

- យោងតាមមាត្រា៦ នៃអនុក្រឹត្យ រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវត្រួតពិនិត្យ និងណែនាំបុគ្គលិក និងបុគ្គលគ្រប់រូប ដែលចូលទៅទីកន្លែងរបស់ខ្លួន ឱ្យធ្វើអនាម័យដើម្បីសម្លាប់មេរោគ វាស់កំដៅ និងពាក់ម៉ាស តាមការកំណត់របស់ក្រសួងសុខាភិបាល។
- ផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលត្រូវចេញប្រកាស ឬសេចក្តីសម្រេច ដើម្បីកំណត់អំពីសហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលត្រូវអនុវត្តកាតព្វកិច្ចទាក់ទងនឹងការពាក់ម៉ាស។ ផ្អែកតាមការកំណត់នេះ សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលបំពាននឹងកាតព្វកិច្ចទាក់ទងនឹងការពាក់ម៉ាស ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖
    - ការបំពានលើកទី១ ៖ ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច
    - ការបំពានចាប់ពីលើកទី២ ៖ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **២ លានរៀល** ទៅ **១០ លានរៀល**។

## ការមិនអនុវត្តកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព *(មាត្រា៧ មាត្រា១៩ និងមាត្រា២០ នៃអនុក្រឹត្យ)*

- យោងតាមមាត្រា៧ នៃអនុក្រឹត្យ ការរក្សាគម្លាតសុវត្ថិភាពបុគ្គល ត្រូវមានយ៉ាងតិច ១,៥០ ម៉ែត្រ។
- **រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម** ត្រូវរៀបចំនៅក្នុងទីកន្លែងរបស់ខ្លួន ដើម្បីធានាថាបុគ្គលិក និងអតិថិជនអាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល នៅពេលរង់ចាំចូល និងពេលកំពុងស្ថិតក្នុងទីកន្លែងរបស់ខ្លួន ព្រមទាំងមិនត្រូវទទួលអតិថិជនលើសពីចំនួនដែលអាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គលនៅក្នុងទីកន្លែងរបស់ខ្លួនឡើយ។
- **អ្នកទទួលខុសត្រូវក្នុងការរៀបចំ**ការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ជាអាទិ៍ កម្មវិធីសាសនា កម្មវិធីប្រពៃណី កម្មវិធីកីឡា ឬកម្មវិធីកំសាន្ត ជាដើម ត្រូវរក្សាគម្លាតសុវត្ថិភាពសង្គម ដោយត្រូវកាត់បន្ថយចំនួនអ្នកចូលរួមឱ្យនៅកម្រិតអប្បបរមា និងចៀសវាងការជួបជុំដែលមានលក្ខណៈកុះករកកកុញ ទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល។
- ផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលត្រូវចេញប្រកាស ឬសេចក្ដីសម្រេច ដើម្បីកំណត់អំពីទីកន្លែងធ្វើការ ទីតាំងអាជីវកម្ម ឬទីកន្លែងសាធារណៈនានាដែលមានមនុស្សច្រើន និងកម្មវិធីជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ដែលត្រូវរក្សាគម្លាតសុវត្ថិភាព។ ផ្អែកតាមការកំណត់នេះ **សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម** និង**អ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត** ដែលបំពាននឹងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖
    - ការបំពានលើកទី១ ៖ ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច
    - ការបំពានចាប់ពីលើកទី២ ៖ ត្រូវផ្ដន្ទាទោសជាពិន័យអន្តរការណ៍
        - ពី **១ លានរៀល** ទៅ **៥ លានរៀល** ចំពោះ**អ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត**។
        - ពី **២ លានរៀល** ទៅ **១០ លានរៀល** ចំពោះ**សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម**។

## ការមិនអនុវត្តកាតព្វកិច្ចសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីយកវត្ថុសំណាក

*(មាត្រា១០ និងមាត្រា២១ នៃអនុក្រឹត្យ)*

- **បុគ្គល** (ដែលមានកាតព្វកិច្ចត្រូវផ្ដល់វត្ថុសំណាក) ដែលមិនសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ត្រូវផ្ដន្ទាទោសជាពិន័យអន្តរការណ៍ពី **១ លានរៀល** ទៅ **៥ លានរៀល**។
- ការបង់ប្រាក់ពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យបុគ្គលដែលប្រព្រឹត្តអំពើល្មើសនេះ រួចផុតពីកាតព្វកិច្ចក្នុងការឱ្យមន្ត្រីសុខាភិបាលយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ នោះទេ។

## ការមិនអនុវត្តកាតព្វកិច្ចក្នុងពេលធ្វើចត្តាឡីស័ក *(មាត្រា១៣ និងកថា.៣ មាត្រា២២ នៃអនុក្រឹត្យ)*

- ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក បុគ្គលដែលធ្វើចត្តាឡីស័ក ត្រូវអនុវត្តកាតព្វកិច្ចដូចជា៖ *(១)- គោរពបទបញ្ជាផ្ទៃក្នុងនៅទីកន្លែងធ្វើចត្តាឡីស័ក, (២)- អនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល តាមការកំណត់របស់ក្រសួងសុខាភិបាល [...]*។
- បុគ្គលដែលមិនអនុវត្តកាតព្វកិច្ចក្នុងពេលធ្វើចត្តាឡីស័កដូចមានកំណត់ក្នុងចំណុចទី១ និងទី២ ខាងលើ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **៥ សែនរៀល** ទៅ **២ លានរៀល**។
- ការបង់ប្រាក់ពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យបុគ្គលដែលត្រូវធ្វើចត្តាឡីស័ក រួចផុតពីកាតព្វកិច្ចក្នុងការធ្វើចត្តាឡីស័កឡើយ។

## ការជួយសម្រួលដល់បុគ្គលណាម្នាក់ឱ្យគេចវេះឬគេចចេញពីការធ្វើចត្តាឡីស័ក *(មាត្រា២៣ នៃអនុក្រឹត្យ)*

**អ្នកផ្តើមគំនិត ដឹកនាំ ណែនាំ បញ្ឆុះបញ្ចូល ឬជួយសម្រួលដោយចេតនា** ដល់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កឱ្យគេចចេញពីការត្រួតពិនិត្យរបស់មន្ត្រីចត្តាឡីស័ក ឬគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក តែមិនបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **១០ លានរៀល** ទៅ **៥០ លានរៀល**។

## ការមិនអនុវត្តកាតព្វកិច្ចក្នុងពេលដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល *(មាត្រា១៤ និងមាត្រា២៤ នៃអនុក្រឹត្យ)*

- ក្នុងអំឡុងពេលដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល អ្នកជំងឺកូវីដ-១៩ ត្រូវអនុវត្តកាតព្វកិច្ចដូចជា៖ *(១)- គោរពបទបញ្ជាផ្ទៃក្នុងនៅទីកន្លែងព្យាបាល, (២)- អនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល តាមការកំណត់របស់ក្រសួងសុខាភិបាល [...]*។
- អ្នកជំងឺកូវីដ-១៩ ដែលមិនអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាលដូចមានកំណត់ក្នុងចំណុចទី១ និងទី២ ខាងលើ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **២ លានរៀល** ទៅ **១០ លានរៀល**។

## ការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ល្មើសនឹងអនុក្រឹត្យ *(មាត្រា១៥ និងមាត្រា២៥ នៃអនុក្រឹត្យ)*

- ការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ដោយមិនអនុញ្ញាតឱ្យគ្រួសារសពជាអ្នកគ្រប់គ្រង និងចាត់ចែងឡើយ។
- បុគ្គលដែលធ្វើការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យ ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **៥ លានរៀល** ទៅ **២០ លានរៀល** (ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត)។

## ការមិនអនុវត្តកាតព្វកិច្ចជូនដំណឹងអំពីករណីដែលពិនិត្យឃើញថាមានអ្នកគេចវេះ ឬគេចចេញពីការធ្វើចត្តាឡីស័ក *(មាត្រា២៦ នៃអនុក្រឹត្យ)*

**គ្រឹះស្ថានសុខាភិបាលឯកជនទាំងអស់** ដែលមិនបានធ្វើការជូនដំណឹងបន្ទាន់ទៅក្រសួងសុខាភិបាល ក្នុងករណីពិនិត្យឃើញថាអ្នកជំងឺដែលកំពុងទទួលសេវាព្យាបាលនៅក្នុងគ្រឹះស្ថានរបស់ខ្លួនមានតម្រុយថាជាអ្នកជំងឺដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬកំពុងគេចចេញពីកន្លែងធ្វើចត្តាឡីស័ក ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី **១០ លានរៀល** ទៅ **៥០ លានរៀល**។

---

**សម្គាល់៖**

- "ច្បាប់" សំដៅដល់ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- "អនុក្រឹត្យ" សំដៅដល់អនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**រៀបចំដោយ៖ ក្រសួងយុត្តិធម៌**